# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ០២ .សរ-២០០២

# <u>សេចក្តីសម្រេច</u>

# នៃ

# សន្និបាតការងារយុត្តិធម៌ឆ្នាំ ២០០១

អង្គសន្និបាតបានដំណើរការអស់រយៈពេលពេញពីរថ្ងៃជាប់គ្នា គឺថ្ងៃទី១៩ និងទី២០ ខែមិនា ឆ្នាំ២០០២ ក្នុងបរិយាកាសរីករាយសាមគ្គី យោគយល់ និងស្និទស្នាលគ្នាជាទីបំផុត ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក អស់លោក ជាចៅក្រមព្រះរាជអាជ្ញានៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ទូទាំងប្រទេស តុលាការយោធា មន្ត្រីរាជការក្រសួងយុត្តិធម៌ មន្ត្រីរាជការមកពីក្រសួងនានាមានតំណាងទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ គណៈកម្មការសិទ្ធិមនុស្សកម្ពុជា ជំនាញការជប៉ុន និងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ។

-ក្រោយពីបានស្តាប់របាយការណ៍សន្និបាតឆ្នាំ ២០០១ និងទិសដៅការងារយុត្តិធម៌ឆ្នាំ២០០២ ។

-ក្រោយពីបានស្តាប់ខ្លឹមសារនៃការពិភាក្សាផ្លាស់ប្តូរយោបល់គ្នាយ៉ាងផុសផុលរបស់សមាជិក សមាជិការ នៃអង្គសន្និបាត ។

អង្គសន្និបាតបានឯកភាពលើរបៀបវារៈ និងរបាយការណ៍សន្និបាតការងារយុត្តិធម៌ឆ្នាំ២០០១ និងទិសដៅការងារយុត្តិធម៌ឆ្នាំ ២០០២ ដោយចាត់ទុកថាជាផែនការចំបងជាការត្រួសត្រាយផ្លូវដ៏ត្រឹមត្រូវទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍន៍ព្រះរាជាណាចក្រកម្ពុជាឱ្យក្លាយទៅជានីតិរដ្ឋដ៏រឹងមាំ។ អង្គសន្និបាតបានសំដែងការពេញចិត្តចំពោះលទ្ធផលដ៏ត្រចះត្រចង់ ដែលជាផ្លែផ្កានៃការពិក្សាផ្លាស់ប្តូរយោបល់គ្នារបស់អង្គសន្និបាត ចងក្រងបានបទពិសោធន៍ការងារបច្ចេកទេសយ៉ាងល្អសម្រាប់ធ្វើជាមូលដ្ឋានដោះស្រាយរឿងក្តី និងទំនាក់ទំនងអន្តរក្រសួងពាក់ព័ន្ធជាមួយសមត្ថកិច្ចតុលាការហើយដែលសុទ្ធតែមានសារៈសំខាន់បំផុត សម្រាប់យកទៅអនុវត្តដោះស្រាយការលំបាកផ្សេងៗ ដែលតុលាការ និងអយ្យការគ្រប់ជាន់ថ្នាក់បានជួបប្រទះកន្លងមក ។

ក្រោយពីអង្គសន្និបាតបានពិភាក្សាប្តូរយោបល់គ្នា យ៉ាងផុសផុលក្បោះក្បាយ ឯកភាពគ្នាទាំងទស្សនៈមតិ និង យោបល់ អង្គសន្និបាតបានសម្រេចដូចខាងក្រោមនេះ ៖

១-អំពីការពិភាក្សា និងផ្តល់យោបល់លើមាត្រា១៥២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដើម្បីកំណត់ទៅលើពាក្យ(គេ) និងពាក្យ(ភ្លាម) ។

**<u>អង្គសន្និបាតសម្រេច</u>**

ពាក្យ(គេ) សំដៅទៅលើតែព្រះរាជអាជ្ញា ឬ តំណាងអយ្យការតែប៉ុណ្ណោះមិនសំដៅទៅលើភាគីដ៏ទៃទៀតនៃរឿងក្តីទេ ។

ពាក្យ(ភ្លាម) សម្រេចយករយៈពេលមួយពេលព្រឹក ឬល្ងាចបន្ទាប់ពីពេលបិទសវនាការទោះបីជាចំលើថ្ងៃបុណ្យ ឬ ថ្ងៃឈប់សម្រាកក៏ដោយ ។

២-អំពីការអនុវត្តន៍សាលក្រមព្រហ្មទណ្ឌទៅលើប្រាក់សំណង និងជម្ងឺចិត្តដែលតុលាការបានសម្រេចឱ្យជនជាប់ចោទសងទៅដើមបណ្តឹងរដ្ឋប្បវេណីចាំបាច់ត្រូវតែដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យអនុវត្ត នោះទើបអ្នកអនុវត្តសាលក្រម អនុវត្តបាន ឬ យ៉ាងណា ? ។

**អង្គសន្និបាតសម្រេច**

ត្រូវតែមានការសុំពីជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី នោះទើបអ្នកអនុវត្តសាលក្រមយកសាលក្រមនោះទៅអនុវត្តអំពីសំណង និង ជម្ងឺចិត្តដែលតុលាការបានសម្រេចជាស្ថាពរហើយនោះបាន ។

៣-មាត្រា ៩០ នៃច្បាប់ស្តីពីវិសោធនកម្មនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០-០១-២០០២ តើព្រះរាជអាជ្ញាដឹកនាំចៅក្រមស៊ើបអង្កេត ឬ យ៉ាងណា ហើយអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍មានសិទ្ធិត្រួតពិនិត្យលើសេចក្តីសម្រេចនានារបស់ចៅក្រមស៊ើបអង្កេត ដោយពុំមានការត្រួតពិនិត្យពីយុត្តាធិការ នៃសាលាឧទ្ធរណ៍ ឬ ទេ ?។

**អង្គសន្និបាតសម្រេច**

ក្នុងករណីព្រះរាជអាជ្ញា ឬ តំណាងអយ្យការមិនប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបអង្កេតទេនោះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬ អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍មានសិទ្ធិទទួលពាក្យបណ្តឹងតវ៉ាពីដើមបណ្តឹងរដ្ឋប្បវេណី ហើយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬ អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍មានសិទ្ធិបង្គាប់ឱ្យព្រះរាជអាជ្ញា ឬ តំណាងអយ្យការផ្សេងទៀត ធ្វើការចោទប្រកាន់តាមអំណាចអធិបញ្ញា ប្រសិនបើយល់ព្រមតាមពាក្យបណ្តឹងតវ៉ានោះ ។

ប្រសិនបើមានការបង្គាប់ផ្ទុយគ្នារវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍សេចក្តីបង្គាប់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មានឧត្តមភាព ។

មាត្រា ៣៦-៣៨ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់នីតិវិធីព្រហ្មទណ្ឌមិនប្រឆាំងទៅនឹងនីតិវិធីព្រហ្មទណ្ឌ ដែលកំពុងអនុវត្តទេ មានន័យថា ព្រះរាជអាជ្ញាជាអ្នកដឹកនាំ និងសម្របសម្រួល ចៅក្រមស៊ើបអង្កេតលើនីតិវិធី និងវិធានស៊ើបអង្កេត ដើម្បីជានាការចោទប្រកាន់ក្នុងភារកិច្ចតែប៉ុណ្ណោះ ។

៤-មាត្រា ៩០ កថាខ័ណ្ឌទី១ ចែងថា តាមគោលការណ៍ដីការបស់ចៅក្រមស៊ើបអង្កេត ត្រូវចែងអំពីមូលហេតុនៃការសម្រេចរបស់ខ្លួន ។ ចំណុចនេះ តើចៅក្រមស៊ើបអង្កេតគ្រាន់តែបញ្ចេញយោបល់យល់ឃើញថា គ្មានពិរុទ្ធភាពធូល្មម តែប៉ុណ្ណោះ ដោយមិនបានលើកយកមូលហេតុសំអាងបាន ឬ ទេ ? ។

**អង្គសន្និបាតសម្រេច**

រក្សារូបមន្ត និង សារាចរផ្សេងៗ របស់ក្រសួងយុត្តិធម៌ ទុកអនុវត្តដដែលរហូតដល់មានច្បាប់ថ្មី ។

៥-មាត្រា ៣៦ បានចែងថា ប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងនោះមានចៅក្រមស៊ើបអង្កេតផងដែរ ។ ដូច្នេះតើការឃុំខ្លួនជនជាប់ចោទលើសកំណត់ច្បាប់របស់ចៅក្រមស៊ើបអង្កេត ជាសមត្ថកិច្ចត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ឬ យ៉ាងណា ? ។

**អង្គសន្និបាតសម្រេច**

ការឃុំខ្លួនជនជាប់ចោទលើសកំណត់ច្បាប់របស់ចៅក្រមស៊ើបអង្កេត ជាសមត្ថកិច្ចត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ផង និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ផង

៦-កថាខ័ណ្ឌទី២ នៃមាត្រា ៣៦ នេះបានចែងដាក់បន្ទុកយ៉ាងធ្ងន់ធ្ងរដល់ព្រះរាជអាជ្ញាខេត្ត-ក្រុង ដែលត្រូវចុះហត្ថលេខាលើកំណត់ហេតុបទល្មើសជាក់ស្តែងក្នុងការដឹកនាំ និងសម្របសម្រួលកិច្ចប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌ តើអង្គសន្និបាតយល់ដូច្នេះដែរ ឬទេ ? ។

**អង្គសន្និបាតសម្រេច**

ផ្អែកតាមកថាខ័ណ្ឌទី២ នៃមាត្រា៣៦ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់នីតិវិធីព្រហ្មទណ្ឌនេះអង្គសន្និបាតយល់ថាជាភារកិច្ចរបស់ព្រះរាជអាជ្ញាដឹកនាំកិច្ចប្រតិបត្តិការនេះហើយ ហើយជាអ្នកត្រូវចូលរួមចុះហត្ថលេខាលើកំណត់ហេតុបទល្មើសជាក់ស្តែង ក្នុងពេលដែលព្រះរាជអាជ្ញាចូលរួមហើយត្រូវចុះហត្ថលេខាតាមឋានានុក្រមក្នុងករណីព្រះរាជអាជ្ញាមិនបានចូលរួមទេ ព្រះរាជអាជ្ញាមិនត្រូវចុះហត្ថលេខាលើកំណត់ហេតុបទល្មើសជាក់ស្តែងរបស់នគរបាលយុត្តិធម៌ទេ ។

៧-ផ្អែកតាមកថាខ័ណ្ឌទី២ នៃមាត្រា ៣៦នេះ តើក្រសួងយុត្តិធម៌អាចកែសម្រួលរបៀបរបបធ្វើការងារជាថ្មី ដោយបំបែកថវិកាចំណាយរបស់តុលាការ និងអយ្យការឱ្យដាច់ពីគ្នា ដើម្បីងាយស្រួលឱ្យព្រះរាជអាជ្ញាចំណាយថវិកានេះបានភ្លាមៗ សម្រាប់បំពេញតួនាទីរបស់ខ្លួនឱ្យបានទាន់ពេលវេលាបាន ឬ ទេ ? ។

**អង្គសន្និបាតសម្រេច**

ចំពោះការសុំបែកថវិកាចំណាយជាពីរ ទៅសាលាជម្រះក្តី អង្គសន្និបាតសម្រេចថា មិនទាន់បំបែកបានទេគឺត្រូវអនុវត្ត និង រក្សាសភាពដូចកន្លងមក ប៉ុន្តែសូមឱ្យលោកប្រធានតុលាការដែលជាអាណាម័កផ្ទេរសិទ្ធិយកចិត្តទុកដាក់ ជួយគិតគូរដល់អយ្យការសម្រាប់ចំណាយផ្សេងៗ អោយមានតម្លាភាព ។

៨-ពិភាក្សាលើមាត្រា៣៦ និង៤៧ នៃច្បាប់ភូមិបាលថ្មីដោយមានតំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ជួយពន្យល់ឱ្យបានក្បោះក្បាយផងអំពីពាក្យ អាជ្ញាធរមានសមត្ថកិច្ច និងខ្លឹមសារនៃមាត្រា៤៧ទាំងមូល។

**អង្គសន្និបាតសម្រេច**

១-ឱ្យអង្គសន្និបាតធ្វើអនុសាសន៍មួយទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនរូបនីយកម្ម និងសំណង់ ដើម្បីឱ្យក្រសួងនេះ ប្រគល់សមត្ថកិច្ចឱ្យសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ទទួលដោះស្រាយបន្តរឿងវិវាទដីធ្លីគ្រប់ប្រភេទរហូតដល់គណៈកម្មការសុរិយោដី បានបង្កើតឡើងតាមអនុក្រឹត្យដែលមានចែងត្រង់ មាត្រា ៤៧ នៃច្បាប់ភូមិបាល ។

២-ចំពោះសំណូមពរដែលក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ សុំឱ្យតុលាការពិនិត្យនិងសម្រេចតែពីសុពលភាព នៃសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដី ដោយមិនបាច់មានសំណុំរឿងរបស់គណៈកម្មការសុរិយោដីនៅពេលភាគីណាមួយមិនសុខចិត្ត និងសេចក្តីសម្រេចនោះហើយប្តឹងទៅតុលាការ ចំណុចនេះអង្គសន្និបាតទាមទារឱ្យគណៈកម្មការសុរិយោដី ត្រូវតែបញ្ជូនសំណុំរឿងស៊ើបអង្កេតរបស់គណៈកម្មការនេះទៅតុលាការប្រសិនបើមានការស្នើសុំដោយពុំមានបដិសេធបានឡើយ ។

៣-គណៈកម្មកាសុរិយោដីត្រូវជូនដំណឹងអំពីសេចក្តីសម្រេចរបស់ខ្លួន ឱ្យបានដល់គូរវិវាទជាអាទិភាពដោយកំណត់រយៈពេលឱ្យគូរភាគី ដែលមិនសុខចិត្តប្តឹងទៅតុលាការក្នុងរយៈពេលមួយឱ្យបានស្របទៅនឹងសិទ្ធិប្តឹងឧទ្ធរណ៍ដែលច្បាប់ជាធរមានបានកំណត់រួចហើយ ។

៤-ចំពោះមាត្រា ៣៦ ផ្អែកតាមការបកស្រាយរបស់តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ដែលបានបញ្ជាក់ថា ពាក្យអាជ្ញាធរមានសមត្ថកិច្ច សំដៅតែទៅលើមន្ត្រីអនុវត្តសាលក្រម នោះឃើញថាពុំមានទំនាស់អ្វីជាមួយច្បាប់ស្តីពីនីតិវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៦-០៤-៩២ នោះទេ ដោយអង្គសន្និបាតបានសំណូមពរឱ្យក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ជួយចែងកំណត់ក្នុងអនុក្រឹត្យ ឬ សេចក្តីពន្យល់ណែនាំឱ្យអនុវត្តច្បាប់ភូមិបាលថ្មីនេះ ទៅនឹងការបកស្រាយខាងលើ ។

សរុបសេចក្តីមក សូមតុលាការ និងអយ្យការ នៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ចូលរួមអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ដើម្បីជាផលប្រយោជន៍ក្នុងការចូលរួមអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ឱ្យបានសម្រេចទៅជានីតិរដ្ឋរឹងមាំ ។

| | |
|---|---|
| **បានឃើញ និង ឯកភាព** | **ប្រធានអនុគណៈកម្មការទទួលបន្ទុក ឯកសារ** |
| **រដ្ឋមន្ត្រី** | **កត់ត្រា និងសរុបលទ្ធផល** |
| **ឆាង ស៊ីផុន** | **អ៊ុំ ប៊ុនធឿន** |